# ការចេញមជ្ឈត្តវិនិច្ឆ័យរបស់ស្ថាប័នម.ជ.ម.កម្ពុជា

## Cambodia Commercial Arbitration Awards Releasing

Two arbitration cases have been made the awards by an Arbitral Tribunal of the National Commercial Arbitration Centre "NCAC", Cambodia, and the other one case is going to be proceeded. Among those cases, disputants are including Cambodian businessman, government agents and foreign companies. This means the Commercial Arbitration skills in Cambodia are interested to use by all appropriating stakeholders, and their awards will be applied to be enforced for the first time of this country.

សំណុំរឿងមជ្ឈត្តការពីរត្រូវបានចេញសេចក្តីសម្រេចបញ្ចប់ (មជ្ឈត្តវិនិច្ឆ័យ) និងសំណុំរឿងមជ្ឈត្តការមួយទៀតកំពុងដំណើរការ, នេះបើតាមការបញ្ជាក់ដោយមជ្ឈមណ្ឌលជាតិនៃ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម កម្ពុជា (ម.ជ.ម.) ។ ក្នុងសំណុំរឿងក្តីនេះ មានខ្លះភាគីជាពាណិជ្ជករខ្មែរ ជារដ្ឋ និងខ្លះទៀតជាពាណិជ្ជករបរទេស ដែលទាំងនេះបង្ហាញឲ្យឃើញថាការដោះស្រាយវិវាទ ពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការត្រូវបានចាប់អារម្មណ៍ពីគ្រប់ភាគីដែលពាក់ព័ន្ធ ។ នាពេលខាង មុខការអនុវត្តមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករដោយបង្ខំ ដែលមានលក្ខណៈជាលើកដំបូងសំរាប់ ជំនាញនេះ និងនៅកម្ពុជា ត្រូវបានគេយកចិត្តទុកដាក់ និង សាកល្បងតាមច្បាប់ផងដែរ ៕

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
NATIONAL COMMERCIAL ARBITRATION CENTRE

លេខ: ០៩៨/ម.ជ.ម./១៧

ថ្ងៃច័ន្ទ ទី៣០ ខែតុលា ឆ្នាំ២០១៧

## សេចក្តីប្រកាសព័ត៌មាន

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ហៅកាត់ថា "ម.ជ.ម.") មានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនសាធារណជនអោយបានជ្រាបថា សំណុំរឿងមជ្ឈត្តកម្មចំនួនពីរគឺ សំណុំរឿងមជ្ឈត្តកម្មលេខ០០២ និងសំណុំរឿងមជ្ឈត្តកម្មលេខ០០៣ ដែលចាត់ចែងដោយ ម.ជ.ម. គឺត្រូវបានបញ្ចប់ដោយជោគជ័យជាស្ថាពរ។ វេទិកាមជ្ឈត្តកម្មដែលត្រូវបានតែងតាំងស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. និងបានចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរចំនួនពីរដូចខាងក្រោម៖

(១) សំណុំរឿងមជ្ឈត្តកម្មលេខ០០២ ត្រូវបានបញ្ជូនមក ម.ជ.ម. កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦។ សំណុំរឿងនេះគឺទាក់ទងនឹងវិវាទពាណិជ្ជកម្ម ដែលកើតឡើងពីការអនុវត្តកិច្ចសន្យាផ្គត់ផ្គង់ ដែលគ្រប់គ្រងដោយច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ដែលភាគីវិវាទគឺក្រុមហ៊ុនខ្មែរ និងស្ថាប័នរដ្ឋ។ វេទិកាមជ្ឈត្តកម្មដែលមានមជ្ឈត្តករចំនួន ៣ (បី)រូប បានដឹកនាំដំណើរការនីតិវិធីមជ្ឈត្តការជាភាសាខ្មែរ។ ការជ្រើសរើសយន្តការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការដែលចាត់ចែងដោយ ម.ជ.ម. មានចែងនៅក្នុងកិច្ចសន្យាដែលមានវិវាទ។

(២) សំណុំរឿងមជ្ឈត្តកម្មលេខ០០៣ ត្រូវបានបញ្ជូនមក ម.ជ.ម. កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦។ សំណុំរឿងនេះគឺទាក់ទងនឹងវិវាទពាណិជ្ជកម្ម ដែលកើតឡើងពីការអនុវត្តកិច្ចសន្យាសាងសង់ ដែលគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ការជ្រើសរើសយន្តការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការដែលចាត់ចែងដោយម.ជ.ម. មានចែងនៅក្នុងកិច្ចសន្យាដែលមានវិវាទ។

ភាគីវិវាទគឺក្រុមហ៊ុនខ្មែរ និងក្រុមហ៊ុនបរទេស។ វេទិកាមជ្ឈត្តកម្មដែលមានមជ្ឈត្តករចំនួន ៣ (បី) រូប បានដឹកនាំដំណើរការនីតិវិធីមជ្ឈត្តការជាភាសាអង់គ្លេស ដែលជាភាសាមួយដែលជ្រើសរើសដោយភាគីវិវាទ។ មជ្ឈត្តវិនិច្ឆ័យក៏ត្រូវបានធ្វើឡើងជាភាសាអង់គ្លេសផងដែរ។ នៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី វេទិកាមជ្ឈត្តកម្មក៏បានចេញវិធានការបណ្តោះអាសន្នតាមការស្នើសុំពីភាគីមួយនៃវិវាទផងដែរ។

បច្ចុប្បន្នសំណុំរឿងក្តីមជ្ឈត្តកម្ម០០៤ បាននឹងកំពុងដំណើរការតាមវិធាន ម.ជ.ម. ផងដែរ។

សមិទ្ធិផលនាថ្ងៃនេះគឺជាជំហានជោគជ័យមួយដ៏ធំជាប្រវត្តិសាស្ត្ររបស់ ម.ជ.ម.។ នេះ សបង្ហាញអោយឃើញថា ម.ជ.ម. ជាស្ថាប័នមជ្ឈត្តការមួយដែលមានសមត្ថភាពក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនដល់វិនិយោគិននានា ដែលប្រកបធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងវិវាទដែលមានភាពស្មុគស្មាញ និងអន្តរវប្បធម៌។

ក្នុងនាមជាស្ថាប័នមជ្ឈត្តការមួយឯករាជ្យ ម.ជ.ម. ប្តេជ្ញាក្នុងការជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការដែលមានគុណភាពខ្ពស់។

ព្រះរាជាណាចក្រកម្ពុជាគឺជារដ្ឋហត្ថលេខីនៃអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ១៩៥៨ ស្តីអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តការបរទេស។ ហេតុដូចនេះ មជ្ឈត្តវិនិច្ឆ័យស្ថាពរដែលចេញដោយ ម.ជ.ម. គឺអាចអនុវត្តបាននៅក្នុងប្រទេសហត្ថលេខីចំនួន ១៥៧ ផ្សេងទៀត។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនងទៅ៖

លោក **រស់ មនិន្ទ** ប្រធាន ម.ជ.ម.

ទូរស័ព្ទលេខ៖ ០១២ ៨៥៥ ៤៧៤ ឬសារអេឡិចត្រូនិក៖ info@ncac.org.kh

---

*អំពីម.ជ.ម.*

*ម.ជ.ម. ត្រូវបានបង្កើតឡើងស្របតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងបានចាប់ផ្តើមដំណើរការជាផ្លូវការនៅខែមករា ឆ្នាំ២០១៣។ ម.ជ.ម គឺជាស្ថាប័នស្វ័យគ្រប់គ្រងដែលមិនស្វែងរកប្រាក់ចំណេញ និងមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ម.ជ.ម. មានបេសកកម្មក្លាយខ្លួនជាអ្នកផ្តល់សេវាដោះស្រាយវិវាទពាណិជ្ជកម្មឈានមុខគេប្រកបដោយចាប់បើស និងចំណាយអស់តិច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងកេរ្តិ៍ឈ្មោះក្នុងការផ្តល់សេវាសន្ទានកម្ម និងមជ្ឈត្តការ ដោយឥតលម្អៀង និងឯករាជ្យ។ ដើម្បីសម្រេចបាននូវបេសកកម្មនេះ ម.ជ.ម. មានគោលបំណងយុទ្ធចំនួនពីរគឺ(១) អភិវឌ្ឍសមត្ថភាពស្ថាប័នរបស់ ម.ជ.ម. និងកសាងសមត្ថភាពបុគ្គលិករបស់ខ្លួន សមាជិកជាមជ្ឈត្តការ និងភាគីពាក់ព័ន្ធ និង(២) គាំទ្រការអភិវឌ្ឍបរិយាកាសដែលផ្តល់ភាពអនុគ្រោះចំពោះការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ (ADR) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលដំណើរការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ (ADR) ត្រូវបានគាំទ្រដោយតុលាការ និងភាគីផ្សេងៗទៀត។ បច្ចុប្បន្ននេះ ម.ជ.ម. មានសមាជិក ៤៨ រូបជាមជ្ឈត្តការ និង១០ ជាសមាជិកនីតិបុគ្គល។*